Long Beach Unified School District

**Beach Independent Study (IS) Program, TK-12**

ខែសីហា 2021

**ជម្រាបជូនមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស:**

សម្រាប់ឆ្នាំសិក្សា 2021-2022 គឺយើងកំពុងបើកការជ្រើសរើសយកកម្មវិធីរៀនជាឯករាជ្យភាព (Independent Study) ទៅកាន់សិស្ស និង ក្រុមគ្រួសារទាំងឡាយណា ដែលមិនចង់ឱ្យសិស្សរបស់ខ្លួនត្រឡប់ចូលសាលារៀនវិញ ។ អ្នកនឹងមានឱកាសជ្រើសរើសចុះឈ្មោះឱ្យសិស្ស របស់អ្នករៀនជាមួយកម្មវិធី TK-12 Independent Study ជំនួសការបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់ ។ សំបុត្រនេះនឹងពន្យល់អំពី:

- សិទ្ធិរបស់អ្នកសម្រាប់ការស្នើសុំជួបប្រជុំរវាង មាតាបិតា-អ្នកផ្តល់ឱវាទ/នាយកសាលារៀន មុននឹងចុះឈ្មោះ ដើម្បីគិតគូរសម្រេច មើលសិន ។
- ដំណើរការ និង សិទ្ធិនៃសិស្សរបស់អ្នក ដែលទាក់ទងមកលើការចុះឈ្មោះ ការដកឈ្មោះចេញ និង ការចុះឈ្មោះឡើងវិញជាមួយ កម្មវិធីរៀនជាឯករាជ្យភាព ។
- ពេលវេលាបង្ហាត់ ដែលសិស្សរបស់អ្នកនឹងមានឱកាសទទួលក្នុងមួយចំណែកនៃកម្មវិធីរៀនជាឯករាជ្យភាព ។

**<u>ការស្នើសុំជួបប្រជុំរវាង មាតាបិតា-អ្នកផ្តល់ឱវាទ/នាយកសាលារៀន</u>**

អ្នកមានសិទ្ធិស្នើសុំជួបប្រជុំរវាង មាតាបិតា-អ្នកផ្តល់ឱវាទ/នាយកសាលារៀន មុននឹងចុះឈ្មោះ ដើម្បីគិតគូរសម្រេចមើលសិនអំពីកម្មវិធីរៀន ជាឯករាជ្យភាព និង ដើម្បីបញ្ជាក់ឱ្យដឹងថា កម្មវិធីនេះ គឺត្រឹមត្រូវមែន ឬ មិនមែនសម្រាប់សិស្សរបស់អ្នក ។

ដើម្បីស្នើសុំការជួបប្រជុំ គឺសូមទាក់ទងទៅកាន់ការិយាល័យចុះឈ្មោះនៅតាមសាលារៀននៃសិស្សរបស់អ្នក និង សុំណាត់ពេលជួបជាមួយ នាយកសាលារៀន ឬ អ្នកផ្តល់ឱវាទ ដែលមានមុខងារជួយបង្ហាញអ្នកអំពីកម្មវិធីរៀនជាឯករាជ្យភាព និង ពន្យល់ជូនអំពីអ្វីត្រូវធ្វើជាបន្ថែម សម្រាប់ការចុះឈ្មោះចូលរួម បើសិនជាអ្នកពេញចិត្ត ។

**<u>ការចុះឈ្មោះចូលរៀន ការដកឈ្មោះចេញ និង ការចុះឈ្មោះចូលរៀនឡើងវិញ</u>**

បន្ទាប់ពីអ្នកបានសម្រេចថា ពេញចិត្តមកលើកម្មវិធីរៀនជាឯករាជ្យភាពហើយ គឺអ្នកអាចចាប់ផ្តើមចុះឈ្មោះបាន ។

អ្នកផ្តល់ឱវាទ ឬ នាយកនៅតាមសាលារៀនសព្វថ្ងៃនៃសិស្សរបស់អ្នកនឹងផ្ញើបញ្ជូនសំណុំរឿងទៅកាន់សាលារៀន Beach IS បន្ទាប់ពីបានធ្វើ ការចាត់ចែងមកលើសិស្សរបស់អ្នកផុតទៅ ។ បុគ្គលិកនៅតាមសាលារៀន Beach នឹងទាក់ទងទៅកាន់អ្នក ដើម្បីណាត់ពេលជួបសម្រាប់ការ ពិគ្រោះរវាង សិស្ស-មាតាបិតា-គ្រូបង្រៀន និង ការចុះហត្ថលេខាយល់ព្រម ។

បន្ទាប់ពីអ្នកបានចុះឈ្មោះជាមួយកម្មវិធីរៀនជាឯករាជ្យភាពផុតទៅ ហើយក៏នឹកចង់ឱ្យសិស្សរបស់អ្នកត្រឡប់ចូលរៀននៅក្នុងថ្នាក់ធម្មតាផ្ទាល់ វិញ គឺអ្នកត្រូវធ្វើតាមវិធីដកឈ្មោះចេញ ។

ដើម្បីស្នើសុំឱ្យមានការត្រឡប់ចូលរៀននៅក្នុងថ្នាក់ធម្មតាផ្ទាល់វិញបាន គឺអ្នកត្រូវផ្ញើ អ៊ីម៉ែល ទៅកាន់អ្នកផ្តល់ឱវាទ ឬ នាយកសាលារៀន Beach ដោយរៀបរាប់បង្ហាញជាឈ្មោះនៃសិស្សរបស់អ្នក និង មូលហេតុសម្រាប់ការស្នើសុំដក ដែលរាប់បញ្ចូលផងទាំងព័ត៌មានងាយទាក់ទង ទៅកាន់អ្នក ។ ក្រសួងអប់រំ ឌីស្រ្ទីគ នឹងប្រឹងប្រែងរកកន្លែងឱ្យសិស្សចូលរៀននៅតាមសាលាដើម បើសិនជាសិស្សនឹកចង់ត្រឡប់ទៅចូលរៀន នៅក្នុងថ្នាក់ធម្មតាផ្ទាល់វិញ ប៉ុន្តែ ដោយគ្មានការធានា ។ បើសិនជាសិស្សនឹកចង់ត្រឡប់ទៅកាន់កម្មវិធីរៀនជាឯករាជ្យភាពវិញ គឺការចុះ ឈ្មោះចូលរៀនឡើងវិញនឹងចាប់ផ្តើមធ្វើ ។

**<u>ពេលវេលាបង្ហាត់</u>**

គោលដៅនៃកម្មវិធីរៀនជាឯករាជ្យភាព (Independent Study) គឺផ្តល់ជំនួសមកលើការបង្ហាត់មេរៀនផ្ទាល់នៅក្នុងថ្នាក់ទៅកាន់សិស្សទាំងឡាយណា ដែលប្រហែលជាមានបញ្ហាផ្នែកសុខភាព នៅពេលរៀនជុំគេឯងក្នុងថ្នាក់ផ្ទាល់ ។ យោងដូច្នេះ កម្មវិធីរៀនជាឯករាជ្យភាព គឺជាកម្មវិធីផ្តល់ការបង្ហាត់មេរៀន ស្របខ្នាតគំរូរបស់រដ្ឋ ដែលមានគ្រូបង្រៀនពេញច្បាប់មើលខុសត្រូវ ។ មានការចែងតម្រូវច្បាស់លាស់មកលើពេលវេលាបង្ហាត់ ដែលរាប់បញ្ចូលផងទាំងមេរៀនបង្ហាត់ឱ្យឃើញភ្លាមៗ និង មេរៀនបង្ហាត់ដាក់ឱ្យធ្វើតាមក្រោយ ។ អ្វីសង្ឃឹមធ្វើតាមទាំងអស់នេះ គឺមានបញ្ជាក់នៅក្នុងសំណុំរឿងយល់ព្រមសម្រាប់សិស្ស ដែលត្រូវបង្ហាញជាការចុះហត្ថលេខាយ៉ាងត្រឹមត្រូវផង មុននឹងអាចចុះឈ្មោះបាន ។

| ពេលវេលាបង្ហាត់ | ការរៀបរាប់ | ប្រវែង និង ភាពញឹកញាប់ស្របតាមកម្រិតថ្នាក់ |
|---|---|---|
| ពេលវេលាបង្ហាត់មេរៀនបង្ហាញឱ្យឃើញភ្លាមៗ<br>Synchronous | នេះជាការបង្ហាត់មេរៀនស្រដៀងគ្នានឹងការបង្ហាត់មេរៀននៅក្នុងថ្នាក់ធម្មតា ឬ ការរៀបចំបង្ហាត់ជាក្រុមតូចៗ ឬ ម្នាក់-ទល់-ម្នាក់ ដោយមនុស្សផ្ទាល់ តាមរយៈ អ៊ីនធ័រណិត ឬ ការនិយាយឆ្លងឆ្លើយគ្នាភ្លាមៗតាមទូរស័ព្ទរវាងគ្រូបង្រៀន និង សិស្ស ។ គ្រូបង្រៀនម្នាក់ ឬ ច្រើននាក់នឹងផ្តល់ការបង្ហាត់មេរៀនបង្ហាញភ្លាមៗទៅកាន់សិស្សនោះ ។ | **<u>ថ្នាក់ TK – 5</u>** *60 នាទី ក្នុងមួយថ្ងៃ*<br><br>**<u>ថ្នាក់ទី 6 - 12</u>** *30 នាទីរាល់សប្តាហ៍នៅតាមថ្នាក់និមួយៗ* |
| ការជួបជជែកគ្នាផ្ទាល់<br>Live Interaction | ការជួបជជែកគ្នាផ្ទាល់រវាងសិស្ស និង បុគ្គលិកប្រចាំសាលារៀន ឬ គ្រូបង្រៀន ដែលអាចរាប់បញ្ចូលផងទាំងសិស្សដូចគ្នា ដើម្បីបង្កើតជាទំនាក់ទំនងក្នុងសាលារៀន ដូចជាៈ ការតាមដានផ្នែកសុខភាព ការតាមដានភាពលូតលាស់ទូទៅ និង ការតាមដានផ្នែកផ្តល់ជំនួយ និង មេរៀនបង្ហាត់ ។ ការជួបជជែកគ្នាផ្ទាល់ គឺអាចធ្វើបានតាមរយៈណាត់ពេលជួបនៅតាមកន្លែង ប្រើ អ៊ីនធ័រណិត ឬ ប្រើទូរស័ព្ទជជែកឆ្លងឆ្លើយ ។ | **<u>ថ្នាក់ TK - 8</u>**<br>*រាល់ថ្ងៃ* |
| ពេលវេលាបង្ហាត់មេរៀន ដែលដាក់កិច្ចការសម្រាប់ធ្វើតាមក្រោយ<br>Asynchronous | ការបង្ហាត់មេរៀនជារបៀបនេះ គឺនឹងមិនកើតឡើងក្នុងកន្លែងតែមួយ ឬ ពេលវេលាតែមួយដូចគ្នានោះទេ ។ នេះជាការបង្ហាត់មេរៀន ដែលសិស្សនឹងរៀនជាមួយតាមរយៈ អនទ្បាញ និង ប្រើឧបករណ៍ ឌីជីតូល ដូចជាៈ មេរៀនថតស្រាប់មកហើយសម្រាប់ចាក់បង្ហាត់ក្នុង វិដេអូ ឬ មេរៀនទាក់ទង ហ្គេម ដែលមានកិច្ចការសម្រាប់សិស្សបំពេញតាមដោយខ្លួនគេ ដោយគ្មានមនុស្សធំនៅក្បែរភ្លាមៗសម្រាប់ជួយ ។ ការបង្ហាត់មេរៀនជារបៀបនេះក៏ទាក់ទងច្រើនដែរមកលើការជួបគ្នា ដូចជាៈ តាមរយៈឆ្លងឆ្លើយ អ៊ីមែល រវាងគ្រូ និង សិស្ស ការតាំងពិគ្រោះ អនទ្បាញ និង ប្រព័ន្ធគ្រប់គ្រងថ្នាក់ផ្សេងៗ ដែលផ្តល់ជាឧបករណ៍បង្ហាត់ និង ការទាក់ទងទៅមក រួមទាំងអ្វីជាបន្ថែមទៀត ។ | <u>ពេលវេលាតិចបំផុតៈ</u><br><br>**<u>ថ្នាក់ TK - 5</u>**<br>*2 ម៉ោង 30 នាទីក្នុងមួយថ្ងៃ ទៅ 5 ម៉ោងក្នុងមួយថ្ងៃ*<br><br>**<u>ថ្នាក់ទី 6 - 12</u>**<br>*4 ម៉ោង ក្នុងមួយថ្ងៃ ទៅ 6 ម៉ោងក្នុងមួយថ្ងៃ* |
| ការជួបប្រជុំគ្នាផ្ទាល់ជាមួយគ្រូបង្រៀន | ការពិគ្រោះឆ្លងឆ្លើយរវាងគ្រូ និង សិស្ស ដើម្បីធ្វើការសើរើមើលអំពីភាពលូតលាស់ផ្នែកសិក្សានៃសិស្ស និង ការផ្តល់ជំនួយផ្នែកសុខភាព ។ | **<u>កម្រិតថ្នាក់ទាំងអស់</u>**: *ជួបប្រជុំគ្នាផ្ទាល់ចំនួនមួយលើកក្នុងមួយខែ* |

មាតាបិតា ឬ អ្នកគ្រប់គ្រងនៃសិស្សអាចជ្រើសរើសកម្មវិធីបង្ហាត់មេរៀនមួយណា ដែលស្របតាមសេចក្តីត្រូវការនៃសិស្សរបស់ពួកគេ ។ បើសិនជាមានសំនួរផ្សេងៗ គឺសូមទាក់ទងទៅកាន់អ្នកផ្តល់ឱវាទ ឬ នាយកនៅតាមសាលារៀននៃសិស្សរបស់អ្នក ។